00657170

E9/16/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / 03 / 2011
ម៉ោង (Time/Heure): 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

ចំពោះមុខ:
ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម **Silvia CARTWRIGHT**
ចៅក្រម **យ៉ា សុខន**
ចៅក្រម **Jean-Marc LAVERGNE**
ចៅក្រម **ធូ មណី**

កាលបរិច្ឆេទ: ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១
ភាសាដើម: ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើសំណើនានាដែលបានស្នើសុំពន្យារពេលដើម្បីដាក់បញ្ជីឯកសារ និងវត្ថុតាង

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅសៀង
Diana ELLIS
ស សុវ៉ាន
Jaques VERGÈS
Philippe GRÉCIAN

00657171

០០២/១៩-០៩-២០០៧-អវតក/អជសដ

**E9/16/4**

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩-៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ អនុលោមតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលអង្គបុរេជំនុំជម្រះបានចេញនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១[1]។

**បានឃើញ** សំណើរបស់ អៀង សារី សុំពន្យារពេលដាក់បញ្ជីឯកសារ និងភស្តុតាង ដែលសំណើនោះស្នើសុំពន្យាពេលក្នុងការដាក់នូវបញ្ជីឯកសារ និងភស្តុតាង បន្ទាប់ពីការិយាល័យសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បញ្ជីឯកសារ និងភស្តុតាងរបស់ខ្លួន ឬជាជម្រើសមួយទៀតមេធាវីការពារក្តីសុំពន្យាពេលដល់ ៦០ថ្ងៃ គិតចាប់ពីថ្ងៃដែលអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីទាក់ទងនឹងរចនាសម្ព័ន្ធនៃការជំនុំជម្រះ និងលំដាប់លំដោយនៃអង្គហេតុដែលត្រូវលើកយកមកពិភាក្សាដេញដោល ("សំណើរបស់ អៀង សារី")[2] ។

**កត់សម្គាល់ឃើញថា** មេធាវីការពារ ខៀវ សំផន ក៏បានដាក់ផងដែរនូវសំណើសុំពន្យាពេលដើម្បីដាក់នូវបញ្ជីឯកសារ និងវត្ថុតាង ដោយបានលើកឡើងនូវទឡ្ហីករណ៍មួយចំនួនដូចគ្នាទៅនឹងទឡ្ហីករណ៍នៅក្នុងសំណើរបស់ អៀង សារី[3] ដែរ។

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26 ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/4/14។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/9 ។

[2] សំណើរបស់ អៀង សារី សុំពន្យារពេលដាក់បញ្ជីឯកសារ និងភស្តុតាង ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ E9/16។

[3] សំណើសុំពន្យាពេលដាក់បញ្ជីឯកសារ និងវត្ថុតាង របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ E9/16/2។

**កត់សម្គាល់ផងដែរលើ** សំណើរបស់ អៀង សារី ដែលត្រូវបានគាំទ្រដោយមេធាវីការពារក្តី នួន ជា និង អៀង ធីរិទ្ធ[4]។

**បានឃើញ** ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ (ឯកសារលេខ E9) ដែលបានតម្រូវឱ្យភាគីដាក់នូវបញ្ជីឯកសារ និងវត្ថុតាងរបស់ខ្លួនដោយមិនឱ្យលើសពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១១ (បន្ទាប់មកបានធ្វើការកែប្រែរហូតដល់ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ក្រោយពីមានសេចក្តីជូនដំណឹងរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការឈប់សម្រាករបស់ចៅក្រម)[5]។

**យល់ឃើញថា** នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថាអង្គជំនុំ-ជម្រះនឹងបដិសេធសំណើទាំងអស់ ដែលស្នើសុំអនុម័តយកនីតិវិធីថ្មីមួយជំនួសឱ្យនីតិវិធីដូចដែលមានចែងក្នុងវិធានផ្ទៃក្នុងបច្ចុប្បន្ន[6]។

**យល់ឃើញផងដែរថា** ក្រុមមេធាវីការពារក្តីបានទទួលនូវការជូនដំណឹងអំពីកាលបរិច្ឆេទចុងក្រោយដែលបានកំណត់ដោយដីកាសម្រេចរបស់អង្គជំនុំជម្រះចាប់តាំងពីថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ហើយក្រុមមេធាវីការពារក្តីមានលទ្ធភាពអាចចូលមើលសំណុំរឿងបានចាប់តាំងពីថ្ងៃចាប់ផ្តើមនៃការ

---

[4] ការជូនដំណឹងអំពីការចូលរួមនឹងសំណើរបស់លោក អៀង សារី សុំពន្យារពេលដាក់បញ្ជីឯកសារ និងភស្តុតាង, ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ E9/16/1, ញត្តិរបស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ ដើម្បីគាំទ្រទៅនឹង "សំណើរបស់មេធាវីការពារក្តីលោក អៀង សារី ស្នើសុំបន្ថែមពេលវេលាដើម្បីដាក់បញ្ជីឯកសារ និងវត្ថុតាង", ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ E9/16/3។

[5] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ,ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ E9, អនុស្សរណៈស្តីពីការឈប់សម្រាករបស់ចៅក្រមក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ, ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ E68។

[6] ការជូនដំណឹងជាមុនអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទាក់ទងនឹងឯកសារដែលមានលេខ E14, E15, E9/2, E9/3, E24 និង E27, ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ E35។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យារពេលដាក់ឯកសារ វត្ថុតាង", ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ E9/6/1។

បំពេញកិច្ចស៊ើបសួរ ដូច្នេះក្រុមមេធាវីការពារក្តីមិនអាចអះអាងថាខ្លួនមិនមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការការពារក្តីរបស់ខ្លួនបានឡើយ[7]។

**ហេតុដូច្នេះសម្រេច**

**បដិសេធ** លើសំណើសុំរបស់ អៀង សារី និង ខៀវ សំផន។

ភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១
ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

**និល ណុន**

[7] *សូមមើលផងដែរនូវ* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យារពេលដើម្បីដាក់ការជំទាស់ទៅលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ឯកសារលេខ (E9/7 និង E9/4/9) ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ E9/7/1។